**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ 368 សហវ.ប្រក

# ប្រកាសរួម

## ស្តីពី

## ការផ្តល់ឋានានុក្រមលើការគ្រប់គ្រង និងការប្រមូលចំណូល
## ពីកម្រៃសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០, មាត្រា ៣៤, មាត្រា ៣៨, មាត្រា ៥០, មាត្រា ៦៦, មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិសារពើពន្ធ
- បានឃើញបទបញ្ញាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ៦៤៥. សហវ.ប្រក ចុះថ្ងៃទី...០៧... ខែ.កក្កដា. ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ១ .–**

ត្រូវបានផ្តល់ថវិការង្វាន់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធ លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ចំណាយឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀតលើការបម្រើសេវាសាធារណៈ និងចំណាយពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ២ .–**

ការផ្តល់ថវិការង្វាន់នេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នារវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ៣ .–**

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត បុរេប្រទានថវិការង្វាន់ពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីកម្រៃសេវាសាធារណៈ ដែលកំណត់ដោយប្រកាសរួមលេខ៦៤៥សហវ.ប្រក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ថវិការង្វាន់ដែលអនុញ្ញាតឱ្យបុរេប្រទាននេះ រួមមានចំណែកថវិការង្វាន់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងចំណែកថវិការង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចំណែកថវិការង្វាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធ។

**ប្រការ៤ .–**

ការផ្តល់ថវិការង្វាន់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ទាំងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត) និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលដែលប្រមូលបាន ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៥ .–**

រដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវគ្រោងចំណាយថវិការង្វាន់នៅក្នុងគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។

រដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវគ្រោងចំណាយថវិការង្វាន់ ដោយគិតបញ្ចូលរួមទាំងថវិការង្វាន់របស់រដ្ឋបាលកណ្តាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងថវិការង្វាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធ។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវគ្រោងចំណាយថវិការង្វាន់ ដោយគិតបញ្ចូលរួមទាំងថវិការង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងថវិការង្វាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធ។ ថវិការង្វាន់ដែលបានគ្រោង ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលបានបុរេប្រទានពីចំណូលថវិកាជាតិ។

រាល់ប្រតិបត្តិការចំណាយថវិការង្វាន់ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងចំណាយថវិកាជាតិ ដូចកិច្ចប្រតិបត្តិការចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តដែរ។

**ប្រការ៦ .–**

ការទូទាត់ថវិកាបុរេប្រទានរង្វាន់លើកទឹកចិត្ត ត្រូវធ្វើឡើងប្រចាំខែ ដោយអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

ក. ផ្នែកចំណូល

ធ្វើសលាកប័ត្រចំណូលថវិកាជាតិនូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន និងសំណើសុំកត់ត្រាចំណូល ÷

- **ចំពោះរដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ :** បញ្ជូនសំណើ និងសលាកប័ត្រចំណូលថវិកាជាតិ មកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។
- **ចំពោះមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត:** បញ្ជូនសំណើ និងសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាង

គណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

ខ. ផ្នែកចំណាយ

រដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវធ្វើសំណើសុំទូទាត់ចំណាយថវិការង្វាន់ និងធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ៧ ._**

ការបើកផ្តល់ថវិការង្វាន់សម្រាប់ឧបត្ថម្ភមន្ត្រីរាជការ ត្រូវអនុវត្តដូចខាងក្រោម ÷

ក. ការបើកផ្តល់ថវិការង្វាន់ជូនមន្ត្រីរាជការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយឈរលើគោលការណ៍សមធមិ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ថវិការង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធមិ និងផ្អែកតាមគុណសម្បត្តិការងារ។

គ. ការបើកផ្តល់ថវិការង្វាន់ជូនមន្ត្រីរាជការនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវអនុលោមតាមការសម្រេចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលរបស់ខ្លួន ដោយឈរលើគោលការណ៍សមធមិ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៨ ._**

ត្រូវបានទិរាករណ៍ប្រកាសរួម ដូចខាងក្រោម ÷

- ប្រកាសរួមលេខ ៩៩៦ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសរួមលេខ ១៣៦៩ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តលើការប្រមូលចំណូលពីការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី..០១... ខែ..កញ្ញា... ឆ្នាំ២០១៧ តទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ.....៦៤៩...... សហវ.ប្រក ចុះថ្ងៃទី..០៧..... ខែ..កក្កដា.. ឆ្នាំ២០១៧

ស្តីពីការផ្តល់ថវិកាទ្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| បរិយាយ | | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| ក. សេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | | | | | | |
| I. សេវាសំណង់ | | | | | | | |
| ១ | លិខិតអនុញ្ញាតសាងសង់ | | | | | | |
| ១.១ | សំណង់លំនៅឋាន | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.២ | សំណង់ចំរុះ | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.៣ | សំណង់ដែលមានឧបនិស្ស័យខាងឧស្សាហកម្ម, ពាណិជ្ជកម្ម, សេវាកម្ម ឬ វិនិយោគ | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.៤ | សំណង់ដែលមានឧបនិស្ស័យខាងអប់រំ វប្បធម៌ និងសុខាភិបាល | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.៥ | សំណង់ដែលមានឧបនិស្ស័យខាងកសិកម្ម | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.៦ | លិខិតអនុញ្ញាតរុះរើ | ១០% | ៨៩% | ១% | - | - | - |
| ១.៧ | លិខិតអនុញ្ញាតជួសជុល | ១០% | ៨៩% | ១% | - | - | - |
| ១.៨ | លិខិតអនុញ្ញាតរុះរើ និងជួសជុល | ១០% | ៨៩% | ១% | - | - | - |
| ១.៩ | លិខិតអនុញ្ញាតរុះរើ ជួសជុល និងសាងសង់ពង្រីកបន្ថែម | ១០% | ៨៩% | ១% | - | - | - |
| ១.១០ | លិខិអនុញ្ញាតសាងសង់ពង្រីកបន្ថែម ឬ បន្ថែមជាន់ | ១០% | ៨៩% | ១% | - | - | - |

| | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| ១.១១ | លិខិតស្នើសុំកែសម្រួលប្លង់សរុប ឬ ប្លង់ស្ថាបត្យកម្ម ឬ ប្តូរសោភ័ណភាព ឬ ប្តូរមុខងារប្រើប្រាស់អគារ | ១០% | ៨៩% | ១% | - | - | - |
| ១.១២ | លិខិតស្នើសុំកែសម្រួលប្លង់សរុប ឬ ប្លង់ស្ថាបត្យកម្ម ឬ ប្តូរសោភ័ណភាព ឬ ប្តូរមុខងារប្រើប្រាស់អគារ | ១០% | ៨៩% | ១% | - | - | - |
| ១.១៣ | លិខិតស្នើសុំធ្វើនិយ័តកម្ម ចំពោះសំណង់ដែលបានសាងសង់រួច | ១០% | ៨៩% | ១% | - | - | - |
| ១.១៤ | លិខិតអនុញ្ញាតបើកការដ្ឋាន | ១០% | ៨៩% | ១% | - | - | - |
| ១.១៥ | វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ និងបិទការដ្ឋាន | ១០% | ៨៩% | ១% | - | - | - |
| ១.១៦ | ប្តូរឈ្មោះក្នុងលិខិតអនុញ្ញាតសាងសង់ និងប្លង់ស្ថាបត្យកម្ម | ១០% | ៨៩% | ១% | - | - | - |
| ១.១៧ | ប្តូរឈ្មោះក្នុងលិខិតអនុញ្ញាតបើក ឬ បិទការដ្ឋានសាងសង់ | ១០% | ៨៩% | ១% | - | - | - |
| ១.១៨ | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ | ១០% | ៨៩% | ១% | - | - | - |
| ១.១៩ | បន្តសុពលភាពលិខិតអនុញ្ញាត ដូចមានចែងក្នុងចំណុច ១.៦, ១.៧, ១.៨, ១.៩, ១.១០, ១.១១, ១.១២, ១.១៣ និង ១.១៤ | ១០% | ៨៩% | ១% | - | - | - |
| ១.២០ | សំណង់ដែលមានឧបនិស្ស័យខាងជំនឿសាសនា | - | - | - | - | - | - |
| ១.២១ | សំណង់អគារដែលបំរើសេវាសាធារណៈរបស់រដ្ឋ សំណង់រដ្ឋ សំណង់សម្បទាន សង្គមកិច្ច សប្បុរសជន អង្គការមនុស្សធម៌ អំណោយជូនសហគមន៍ ឬ ជនក្រីក្រ សហគមន៍ អង្គការវេសនដ្ឋានសង្គម....... | - | - | - | - | - | - |
| ២ | សេវាផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដី អតិបរមាផ្លូវការ | ៣០% | ៦៩% | ១% | - | - | - |

| បរិយាយ | | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| ៣ | ការផ្តល់គោលការណ៍សាងសង់ និងអភិវឌ្ឍន៍ដី | ១០% | ៨៩% | ១% | - | - | - |
| ៤ | ការចុះត្រួតពិនិត្យ និងបញ្ជាក់សុវត្ថិភាពសំណង់រោងចក្រផ្នែកវាយនភ័ណ្ឌកាត់ដេរ សំលៀកបំពាក់ និងផលិតស្បែកជើង | ៣០% | ៦៩% | ១% | - | - | - |
| ៥ | ការផ្តល់លិខិតបញ្ជាក់ពីការត្រួតពិនិត្យ និងធ្វើកោសល្យវិច័យសំណង់អគារ | ៣០% | ៦៩% | ១% | - | - | - |
| II. សេវាផ្តល់វិញ្ញាបនបត្រដល់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ សហគ្រាស ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ក្រុមហ៊ុនប្រកបអាជីវកម្មសាងសង់ | | | | | | | |
| ១ | វិញ្ញាបនបត្រលើកដំបូង និងបន្តសុពលភាព សម្រាប់សហគ្រាស ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ | ៥០% | ៤៩% | ១% | - | - | - |
| ២ | បន្តសុពលភាព និង/ ឬ តម្លើងកម្រិតសម្រាប់សហគ្រាល ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ | ៥០% | ៤៩% | ១% | - | - | - |
| ៣ | បន្តសុពលភាព និង/ ឬ បន្ថយកម្រិតសម្រាប់សហគ្រាល ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ | ៥០% | ៤៩% | ១% | - | - | - |
| ៤ | វិញ្ញាបនបត្រលើកដំបូង និងបន្តសុពលភាពសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | ៥០% | ៤៩% | ១% | - | - | - |
| ៥ | បន្តសុពលភាព និង/ ឬ តម្លើងកម្រិតសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | ៥០% | ៤៩% | ១% | - | - | - |
| ៦ | បន្តសុពលភាព និង/ ឬ បន្ថយកម្រិតសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | ៥០% | ៤៩% | ១% | - | - | - |
| ៧ | ចុះបញ្ជីលើកដំបូង បន្តសុពលភាព និងតម្លើងកម្រិតសម្រាប់សហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គប្រកបអាជីវកម្មត្រួតពិនិត្យ និងធ្វើកោសល្យវិច័យលើសំណង់អគារ | ៥០% | ៤៩% | ១% | - | - | - |
| ៨ | ការចេញប័ណ្ណទុតិយតា ឬ តតិយតា ចំពោះគ្រប់ប្រភេទប័ណ្ណ | ៥០% | ៤៩% | ១% | - | - | - |

| បរិយាយ | | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| III. សេវាថតចម្លងឯកសារប្លង់ និងផែនទី | | | | | | | |
| ១ | ឯកសារស្នើសុំសាងសង់ | ១០% | ៨៩% | ១% | - | - | - |
| ២ | ប្លង់ស្ថាបត្យកម្ម ឬ ប្លង់គ្រឿងផ្គុំសំណង់ | ១០% | ៨៩% | ១% | - | - | - |
| ៣ | ផែនទី ទំហំ A-4 | ១០% | ៨៩% | ១% | - | - | - |
| ៤ | ផែនទី ទំហំ A-3 | ១០% | ៨៩% | ១% | - | - | - |
| ៥ | ផែនទី ទំហំ A-2 | ១០% | ៨៩% | ១% | - | - | - |
| ៦ | ផែនទី ទំហំ A-1 | ១០% | ៨៩% | ១% | - | - | - |
| ៧ | ផែនទី ទំហំ A-0 | ១០% | ៨៩% | ១% | - | - | - |
| IV. សេវាពិគ្រោះយោបល់លើផ្នែកច្បាប់ និងបច្ចេកទេស | | | | | | | |
| ១ | លើការងារទាក់ទងទៅនឹងដីធ្លី សំណង់ ទូទៅ | ១០% | ៨៩% | ១% | - | - | - |
| ២ | លើការងារទាក់ទងទៅនឹងតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍកោះ ឆ្នេរ បុរី ដីសម្បទាន សេដ្ឋកិច្ច និងអគារខ្ពស់ៗ | ១០% | ៨៩% | ១% | - | - | - |

| បរិយាយ | | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| ខ. សេវាសាធារណៈដែលផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | | | | | | | |
| I. សេវាសំណង់ | | | | | | | |
| ១ | លិខិតអនុញ្ញាតសាងសង់ | | | | | | |
| ១.១ | សំណង់លំនៅឋាន | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.២ | សំណង់ចំរុះ | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.៣ | សំណង់ដែលមានឧបនិស្ស័យខាងឧស្សាហកម្ម, ពាណិជ្ជកម្ម, សេវាកម្ម ឬ វិនិយោគ | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.៤ | សំណង់ដែលមានឧបនិស្ស័យខាងអប់រំ វប្បធម៌ និងសុខាភិបាល | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.៥ | សំណង់ដែលមានឧបនិស្ស័យខាងកសិកម្ម | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.៦ | លិខិតអនុញ្ញាតរុះរើ | ១០% | ៨៩% | ១% | - | - | - |
| ១.៧ | លិខិតអនុញ្ញាតជួសជុល | ១០% | ៨៩% | ១% | - | - | - |
| ១.៨ | លិខិតអនុញ្ញាតរុះរើ និងជួសជុល | ១០% | ៨៩% | ១% | - | - | - |
| ១.៩ | លិខិតអនុញ្ញាតរុះរើ ជួសជុល និងសាងសង់ពង្រីកបន្ថែម | ១០% | ៨៩% | ១% | - | - | - |
| ១.១០ | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម ឬ ថែមជាន់ | ១០% | ៨៩% | ១% | - | - | - |
| ១.១១ | លិខិតស្នើសុំកែសម្រួលប្លង់សរុប ឬ ប្លង់ស្ថាបត្យកម្ម ឬ ប្តូរសោភ័ណភាព ឬ ប្តូរមុខងារប្រើប្រាស់អគារ | ១០% | ៨៩% | ១% | - | - | - |
| ១.១២ | លិខិតស្នើសុំកែសម្រួលប្លង់សរុប ឬ ប្លង់ស្ថាបត្យកម្ម ឬ ប្តូរសោភ័ណភាព ឬ ប្តូរមុខងារប្រើប្រាស់អគារ | ១០% | ៨៩% | ១% | - | - | - |
| ១.១៣ | លិខិតស្នើសុំធ្វើនិយ័តកម្ម ចំពោះសំណង់ដែលបានសាងសង់រួច | ១០% | ៨៩% | ១% | - | - | - |



ᢂ ꛪ ⊾ ꔰ ⊅

| បរិយាយ | | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| ១.១៤ | លិខិតអនុញ្ញាតបើកការដ្ឋាន | ១០% | ៨៩% | ១% | - | - | - |
| ១.១៥ | វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ និងបិទការដ្ឋាន | ១០% | ៨៩% | ១% | - | - | - |
| ១.១៦ | សំណង់របងរឹងមាំ ធ្វើពីបេតុងដែក និងឥដ្ឋ | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១.១៧ | លិខិតស្នើសុំពង្រីកបន្ថែម រុះរើ ជួសជុល សំណង់របង | ១០% | ៨៩% | ១% | - | - | - |
| ១.១៨ | លិខិតស្នើសុំបើកការដ្ឋានសំណង់របង | ១០% | ៨៩% | ១% | - | - | - |
| ១.១៩ | លិខិតស្នើសុំវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ ឬ បិទការដ្ឋានរបង | ១០% | ៨៩% | ១% | - | - | - |
| ១.២០ | ប្ដូរឈ្មោះក្នុងលិខិតអនុញ្ញាតសាងសង់ និងក្នុងប្លង់ស្ថាបត្យកម្ម | ១០% | ៨៩% | ១% | - | - | - |
| ១.២១ | ប្ដូរឈ្មោះក្នុងលិខិតអនុញ្ញាតបើក ឬ បិទការដ្ឋានសាងសង់ | ១០% | ៨៩% | ១% | - | - | - |
| ១.២២ | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ | ១០% | ៨៩% | ១% | - | - | - |
| ១.២៣ | បន្តសុពលភាពលិខិតអនុញ្ញាត ដូចមានចែងក្នុងចំណុច ១.៦, ១.៧, ១.៨, ១.៩, ១.១០, ១.១១, ១.១២, ១.១៣ និង ១.១៤ | ១០% | ៨៩% | ១% | - | - | - |
| ១.២៤ | សំណង់ដែលមានឧបនិស្ស័យខាងជំនឿសាសនា | - | - | - | - | - | - |
| ១.២៥ | សំណង់អគារដែលបំរើសេវាសាធារណៈរបស់រដ្ឋ សំណង់រដ្ឋ សំណង់សម្បទានសង្គមកិច្ច សប្បុរសជន អង្គការមនុស្សធម៌ អំណោយជូនសហគមន៍ ឬ ជនក្រីក្រ សមាគមន៍ អង្គការ វេសនដ្ឋានសង្គម... | - | - | - | - | - | - |
| ២ | សេវាផ្ដល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្ទៃការ | ៣០% | ៦៩% | ១% | - | - | - |

| បរិយាយ | | អត្រាបែងចែក | | | | | |
| --- | --- | --- | --- | --- | --- | --- | --- |
| | | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| II. សេវាសុរិយោដី និងភូមិសាស្ត្រ | | | | | | | |
| ១ | ការចុះបញ្ជីដីលើកដំបូង ដែលមានលក្ខណៈជាប្រព័ន្ធ | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ២ | ការចុះបញ្ជីដីលើកដំបូងដែលមានលក្ខណៈដាច់ដោយដុំ ឬ ការចុះបញ្ជីដីបំពេញបន្ថែម | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ៣ | ការចុះបញ្ជីលើដីឯកជនរបស់រដ្ឋ ដីគ្រឹះស្ថានសាធារណៈ និងគុរុភណ្ឌជាដីរបស់វត្ត | - | - | - | - | - | - |
| ៤ | ការចេញបណ្ណទុតិយតា ឬ តតិយតា ចំពោះគ្រប់ប្រភេទបណ្ណ | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ៥ | ការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ឬ ភោគៈ ឬ ការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកភោគៈ | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ៦ | ការចុះបញ្ជីអំពីការកែតម្រូវកម្មសិទ្ធិ ឬ ភោគៈ ឬ ការចុះបញ្ជីអំពីការកែតម្រូវចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកភោគៈ | ១០% | ៨៩% | ១% | - | - | - |
| ៧ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ឬ ភោគៈ ឬ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកភោគៈ | ១០% | ៨៩% | ១% | - | - | - |
| ៨ | ការបំបែកក្បាលដីដោយមិនផ្ទេរសិទ្ធិ ប្រសិនបើបំបែកក្បាលដីដោយមានផ្ទេរសិទ្ធិ ត្រូវបូកបន្ថែមតម្លៃសេវា និងរយៈពេលចុះបញ្ជីផ្ទេរសិទ្ធិតាមក្បាលដីនីមួយៗ ដូចមានកំណត់ ក្នុងចំណុចទី៥ | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ៩ | ការបង្រួមក្បាលដី | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១០ | ការស្វែងរកចំណុចព្រំដីឡើងវិញ | ៣០% | ៦៩% | ១% | - | - | - |

| | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | គ ជនស | គ សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| ១១ | ការចេញលិខិតបញ្ជាក់ព័ត៌មានសុរិយោដី | ១០% | ៨៩% | ១% | - | - | - |
| ១២ | ការថតចម្លងឯកសារសុរិយោដី | ១០% | ៨៩% | ១% | - | - | - |
| ១៣ | ការប្តូរប្រភេទដី | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |
| ១៤ | ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ | ៣០% | ៦៩% | ១% | - | - | - |
| ១៥ | ការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជននៃអគារសហកម្មសិទ្ធិ | ៣០% | ៦៩% | ១% | - | - | - |
| ១៦ | ការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ | ៣០% | ៦៩% | ១% | - | - | - |
| ១៧ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជន ឬ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកសិទ្ធិ ជួលអចិន្ត្រៃយ៍អវិភាគលើចំណែកឯកជន | ៣០% | ៦៩% | ១% | - | - | - |
| ១៨ | ក. ការចុះបញ្ជីអំពីការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ និងការចេញវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការចុះបញ្ជីអំពីការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍បន្ត<br>ខ. ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគ<br>គ. ការចុះបញ្ជីអំពីការបង្កើតផលុបភោគ<br>ឃ. ការចុះបញ្ជីអំពីការផ្ទេរផលុបភោគ ឬ ផ្ទេរចំណែកផលុភោគអវិភាគ | ៣០% | ៦៩% | ១% | - | - | - |

| បរិយាយ | | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | ក ដនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| ១៩ | ក. ការចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវអំឡុងពេល ឬ ថ្លៃឈ្នួល ឬ ពេលវេលានៃការបង់ថ្លៃឈ្នួល ឬ ការសន្យាពិសេសនៃសិទ្ធិជួលអចិន្ត្រៃយ៍ | ៣០% | ៦៩% | ១% | - | - | - |
| | ខ. ការចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវអំឡុងពេល ឬ តម្លៃថ្នូរ ឬ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ ការសន្យាពិសេសនៃផលុបភោគ | | | | | | |
| | គ. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍បន្ត ឬ ការចុះបញ្ជីអំពីការលុប ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគ | | | | | | |
| | ឃ. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការបង្កើតផលុបភោគ ឬ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរផលុបភោគ ឬ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការ ផ្ទេរចំណែក ផលុបភោគអវិភាគ | | | | | | |
| ២០ | ក. ការចុះបញ្ជីអំពីការកែតម្រូវសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការកែតម្រូវចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ | ៣០% | ៦៩% | ១% | - | - | - |
| | ខ. ការចុះបញ្ជីអំពីការកែតម្រូវផលុបភោគ ឬ ការកែតម្រូវចំណែកផលុបភោគ | | | | | | |
| ២១ | ការចុះបញ្ជីអំពីសិទ្ធិសម្បទានដីសេដ្ឋកិច្ច | ៣០% | ៦៩% | ១% | - | - | - |

| | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | គ ជនស | គ សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| | ក. ការចុះបញ្ជីអំពីការបង្កើតសេវភាព | | | | | | |
| | ខ. ការចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវអំឡុងពេល ឬ គោលបំណង ឬ ទំហំ ឬ តម្លៃថ្នូរ ឬ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ ការសន្យាពិសេសនៃសេវភាព | | | | | | |
| | គ. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីសេវភាព | | | | | | |
| | ឃ. ការចុះបញ្ជីអំពីការបង្កើតឯកសិទ្ធិ ឬ ការចុះបញ្ជីអំពីការផ្ទេរឯកសិទ្ធិ ឬ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីឯកសិទ្ធិ | | | | | | |
| | ង. ការចុះបញ្ជីអំពីការបង្កើតសិទ្ធិលើការបញ្ចាំ ឬ ការចុះបញ្ជីអំពីការបង្កើតសិទ្ធិលើការបញ្ចាំរួម ឬ ការចុះបញ្ជីអំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត | | | | | | |
| ២២ | ច. ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិលើការបញ្ចាំ | ១០% | ៨៩% | ១% | - | - | - |
| | ឆ. ការចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវសិទ្ធិលើការបញ្ចាំ | | | | | | |
| | ជ. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីសិទ្ធិលើការបញ្ចាំ | | | | | | |
| | ឈ. ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកបន្ត | | | | | | |
| | ញ. ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក | | | | | | |
| | ដ. ការចុះបញ្ជីអំពីឧបាទេសភាគហ៊ីប៉ូតែករួម | | | | | | |
| | ឋ. ការចុះបញ្ជីអំពីអនុប្បទានហ៊ីប៉ូតែក ឬ ការបោះបង់ហ៊ីប៉ូតែក | | | | | | |
| | ឌ. ការចុះបញ្ជីអំពីអនុប្បទានលំដាប់ហ៊ីប៉ូតែក ឬ ការបោះបង់លំដាប់ហ៊ីប៉ូតែក | | | | | | |

| បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|
| | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| ឈ. ការចុះបញ្ជីអំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក | | | | | | |
| ណ. ការចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវហ៊ីប៉ូតែក | | | | | | |
| ត. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែក | | | | | | |
| ថ. ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត | | | | | | |
| ទ. ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត | | | | | | |
| ធ. ការចុះបញ្ជីអំពីការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត | | | | | | |
| ន. ការចុះបញ្ជីអំពីការផ្លាស់ប្តូរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ ការចុះបញ្ជីអំពីកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ ការចុះបញ្ជីអំពីការព្រមព្រៀងគ្នារបស់សន្តតិជននៃម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត និង/ ឬ កូនបំណុល | ១០% | ៨៩% | ១% | - | - | - |
| ប. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត | | | | | | |
| ផ. ការចុះបញ្ជីអំពីការសន្យាពិសេសនៃការលោះ ឬ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការសន្យាពិសេសនៃការលោះ | | | | | | |
| ព. ការចុះបញ្ជីអំពីការហាមបែងចែកអចលនវត្ថុអវិភាគ | | | | | | |
| ភ. ការចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវអំឡុងពេលហាមបែងចែកអចលនវត្ថុអវិភាគ | | | | | | |

| | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| | ម. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការហាមបែងចែកអចលនវត្ថុអវិភាគ | | | | | | |
| | យ. ការចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវឈ្មោះ ឬ ថ្ងៃខែឆ្នាំកំណើត ឬ ទីកន្លែងកំណើត ឬ ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ | | | | | | |
| | រ. ការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ | | | | | | |
| | ល. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ | | | | | | |
| | វ. ការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ | | | | | | |
| | ស. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ | | | | | | |
| | ហ. ការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានបង្កើតលើកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ | ១០% | ៨៩% | ១% | - | - | - |
| | ឡ. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានបង្កើតលើកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ | | | | | | |

<table>
<tr><th rowspan="3">បរិយាយ</th><th colspan="6">អត្រាបែងចែក</th></tr>
<tr><th rowspan="2">ថវិកាជាតិ</th><th rowspan="2">ក ជនស</th><th rowspan="2">ក សហវ</th><th colspan="3">រដ្ឋបាលថ្នាក់ក្រោមជាតិ</th></tr>
<tr><th>រាជធានី ខេត្ត</th><th>ក្រុង ស្រុក ខណ្ឌ</th><th>ឃុំ សង្កាត់</th></tr>
<tr><td>អ. ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតនិងការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគ ផ្សេងៗទៀតដែលបានបង្កើតលើកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ</td><td rowspan="6">១០%</td><td rowspan="6">៨៩%</td><td rowspan="6">១%</td><td rowspan="6">-</td><td rowspan="6">-</td><td rowspan="6">-</td></tr>
<tr><td>ក១. ការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន</td></tr>
<tr><td>ខ១. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន</td></tr>
<tr><td>គ១. ការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានបង្កើតលើកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិ ជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ</td></tr>
<tr><td>ឃ១. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានបង្កើតលើកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ</td></tr>
<tr><td>ង១. ការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ</td></tr>
</table>

| | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| | ច១. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ | ១០% | ៨៩% | ១% | - | - | - |
| | ឆ១. ការចុះបញ្ជីអំពីការបង្កើត ឬ ការកែប្រែ ឬ ការលុបនូវសិទ្ធិតាមសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ | | | | | | |
| ២៣ | ក. ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ការចុះបញ្ជី អំពីការលុបការ ចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន | ១០% | ៨៩% | ១% | - | - | - |
| | ខ. ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ការចុះបញ្ជី អំពីការលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្នដោយការអនុវត្តសិទ្ធិប្រាតិភោគ | | | | | | |
| ២៤ | ផែនទីជាក្រដាស | ១០% | ៨៩% | ១% | - | - | - |
| ២៥ | រូបថតអ័រតូហ្វូតូទម្រង់ឌីជីថល | ១០% | ៨៩% | ១% | - | - | - |
| ២៦ | រូបថតអ័រតូហ្វូតូទម្រង់ជាក្រដាស បោះពុម្ពជាក្រដាសខ្នាត A0 | ១០% | ៨៩% | ១% | - | - | - |
| ២៧ | ទិន្នន័យបង្គោលប្រឹថពីភោគ | ១០% | ៨៩% | ១% | - | - | - |
| ២៨ | ការចុះបញ្ជីផ្ទេរបន្ទុកដោយការបំបែក ឬ បង្រួមក្បាលដី | ១០% | ៨៩% | ១% | - | - | - |
| ២៩ | ការចុះបញ្ជីព័ត៌មានអំពីអាគារ ឬ សំណង់ | ៣០% | ៤៩% | ១% | ៥% | ៥% | ១០% |

| បរិយាយ | | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាជាតិ | ក ជនស | ក សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| **III. សេវាផ្តល់វិញ្ញាបនបត្រដល់ក្រុមជាងសំណង់** | | | | | | | |
| ១ | វិញ្ញាបនបត្រលើកដំបូងសម្រាប់ក្រុមជាងសំណង់ | ៥០% | ៤៩% | ១% | - | - | - |
| ២ | បន្តសុពលភាពសម្រាប់ក្រុមជាងសំណង់ | ៥០% | ៤៩% | ១% | - | - | - |
| ៣ | ការចេញប័ណ្ណទុតិយតា ឬ តតិយតា ចំពោះគ្រប់ប្រភេទប័ណ្ណ | ៥០% | ៤៩% | ១% | - | - | - |
| **IV. សេវាថតចម្លងឯកសារប្លង់** | | | | | | | |
| ១ | ឯកសារស្នើសុំសាងសង់ | ១០% | ៨៩% | ១% | - | - | - |
| ២ | ប្លង់ស្ថាបត្យកម្ម ឬ ប្លង់គ្រឿងផ្គុំសំណង់ | ១០% | ៨៩% | ១% | - | - | - |
| **V. សេវាពិគ្រោះយោបល់លើផ្នែកច្បាប់ និងបច្ចេកទេស** | | | | | | | |
| ១ | លើការងារទាក់ទងទៅនឹងដីធ្លី និងសំណង់ទូទៅ | ១០% | ៨៩% | ១% | - | - | - |

**កំណត់សំគាល់:**

១- ពាក្យ "*ក ជនស*" មានន័យថា រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២- ពាក្យ "*ក សហវ*" មានន័យថា រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣- ការផ្តល់ថវិកាផ្នែកខាងលើនេះ ត្រូវបានលើកលែងចំពោះប្រភេទសេវាសាធារណៈ ដែលបានធ្វើប្រតិភូកម្មឱ្យទៅក្រុង ស្រុក ខណ្ឌ ដែលមានច្រកចេញចូលតែមួយ។